# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**

**និងប្រព័ន្ធយុត្តិធម៌**

**អង្គភាពគ្រប់គ្រងគម្រោង**

**លេខ: ០០៦ /០៩ក.ប.អគគ**

*រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩*

**កំណត់ហេតុ**

**សិក្ខាសាលា**

**ស្តីពីការស្ទង់មតិជាមូលដ្ឋានលើអង្គភាពនីតិកម្ម និងសមត្ថភាពតាក់តែងច្បាប់របស់ ក្រសួងឬស្ថាប័ន នៅសណ្ឋាគារកាំបូឌីយ៉ាណា**

ឆ្នាំពីរពាន់ប្រាំបួន ខែមករា ថ្ងៃទី ម្ភៃបី វេលាម៉ោងប្រាំបីព្រឹក នៅសណ្ឋាគារកាំបូឌីយ៉ាណាមានរៀបចំសិក្ខាសាលាមួយក្រោមអធិបតីភាពរបស់ឯកឧត្តម **ស៊ុយ ម៉ុងលាង** នាយកអង្គភាពគ្រប់គ្រងគម្រោងនៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្តីពីការស្ទង់មតិជាមូលដ្ឋានលើអង្គភាពនីតិកម្ម សមត្ថភាពនីតិកម្ម និងសមត្ថភាពតាក់តែងច្បាប់របស់ក្រសួងឬស្ថាប័ន។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **ស៊ុយ ម៉ុងលាង** បានសម្តែងកិច្ចស្វាគមន៍ចំពោះគណៈអធិបតី ជាពិសេសគឺលោកស្រី Katharina Huebner តំណាងអង្គការកិច្ចសហប្រតិបត្តិការបច្ចេកទេសអាឡឺម៉ង់ដ៍ (GTZ) ព្រមទាំងឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិ និងសមាជិក សមាជិកាដែលមានវត្តមាននាពេលនោះ។ ជាមួយគ្នានោះដែរ ឯកឧត្តមបានថ្លែងអំណរគុណដល់ GTZ ដែលបានជួយគាំទ្រ និងរៀបចំនូវសិក្ខាសាលានេះឡើង ដែលជាសកម្មភាពជាអាទិភាពលេខ ២.៣.៤ កំណត់ក្នុងផែនការសកម្មភាពនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ដែលគណៈរដ្ឋមន្ត្រីបានអនុម័តក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៥។ ឯកឧត្តមបានជម្រាបជូនអង្គសិក្ខាសាលាអំពីយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៤នៃរដ្ឋសភាថា ជាកម្មវិធីនយោបាយមួយដ៏ត្រឹមត្រូវ ដើម្បីធានាបាននូវប្រសិទ្ធភាព

ការងារក្នុងការអនុវត្តកម្មវិធីកំណែទម្រង់លើគ្រប់ផ្នែក គ្រប់វិស័យក្នុងទិសដៅកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចិរភាព។

អង្គសិក្ខាសាលាថ្ងៃនេះ គឺជាលទ្ធផលនៃការអនុវត្តគម្រោងមួយក្នុងចំណោមគម្រោងបីទៀត ដែលកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានចុះអនុស្សរណៈយោគយល់គ្នាជាមួយអង្គការសហប្រតិបត្តិការអាល្លឺម៉ង់ នៅឆ្នាំ ២០០៨ កន្លងទៅ។ នេះជាសក្ខីភាពបញ្ជាក់អោយឃើញនូវឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីឈានទៅរកការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ប្រកបដោយប្រសិទ្ធភាព។

ឯកឧត្តមក៏បានលើកឡើងនូវគោលបំណងនៃសិក្ខាសាលានេះ គឺដើម្បីស្វែងយល់អំពីការខ្វះចន្លោះ នៃអង្គភាពនីតិកម្មនៅតាមក្រសួងស្ថាប័ននីមួយៗ អំពីការរៀបចំផែនការគោលនយោបាយ និងសេចក្តីត្រូវការផ្នែកច្បាប់ ព្រមទាំងអំពីកម្មវិធីបណ្តុះបណ្តាលការងារតាក់តែងច្បាប់ដល់មន្ត្រីអង្គភាពនីតិកម្ម នៅតាមបណ្តាក្រសួង-ស្ថាប័ននោះដែរ។ ហេតុដូច្នេះការរៀបចំការស្ទង់មតិជាមូលដ្ឋានពីសមត្ថភាព នៃការតាក់តែងច្បាប់នៅតាមអង្គភាពនីតិកម្មនៅតាមក្រសួង-ស្ថាប័ននីមួយៗ គឺជាកត្តាចាំបាច់មួយ ដើម្បីពង្រឹងសមត្ថភាពគតិយុត្តិលើគ្រប់វិស័យនៅកម្ពុជា ព្រមទាំងដើម្បីកសាងសង្គមជាតិអោយក្លាយជានីតិរដ្ឋពិតប្រាកដ។

ឯកឧត្តមសង្ឃឹមថា តាមរយៈអង្គសិក្ខាសាលានេះ យើងទាំងអស់គ្នានឹងទទួលបាននូវអនុសាសន៍ដ៏ប្រសើរសម្រាប់ធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ន លើការតាក់តែងច្បាប់របស់ក្រសួង និងស្ថាប័នពាក់ព័ន្ធនឹងដំណើរការតាក់តែងច្បាប់ ហើយនឹងអំពីតម្រូវការ និងរបៀបផ្គត់ផ្គង់ដើម្បីបំពេញសមត្ថភាពការតាក់តែងច្បាប់ ព្រមទាំងអំពីកម្មវិធីបណ្តុះបណ្តាលការងារតាក់តែងច្បាប់ដល់មន្ត្រីនៅតាមអង្គភាពនីតិកម្មតាមក្រសួងស្ថាប័ននីមួយៗ។

ឆ្លៀតឱកាសនោះដែរ ឯកឧត្តមបានថ្លែងអំណរគុណជាថ្មីម្តងទៀតចំពោះអង្គការ GTZ ព្រមទាំងដៃគូអភិវឌ្ឍន៍ និងសប្បុរសជនទាំងឡាយ ដែលបានចូលរួមជាវិភាគទានដ៏ថ្លៃថ្លាទាំងកំលាំងកាយចិត្ត ពេលវេលា ថវិកា សម្ភារៈ និងបច្ចេកទេស ក្នុងការជួយឧបត្ថម្ភគាំទ្រដល់កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌នេះ។

ជាបន្ទាប់ឯកឧត្តម **ស្វួន លាងហៃ** នាយករងអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុុត្តិធម៌ បានធ្វើបទបង្ហាញជូនអង្គសិក្ខាសាលាអំពីការរៀបចំគម្រោងស្ទង់មតិខាងលើនេះ។ ឯកឧត្តមបានមានប្រសាសន៍ថា សិក្ខាសាលាថ្ងៃនេះគឺជាសកម្មភាពមួយ ដែលអនុវត្តឡើងយោងទៅសកម្មភាពជាអាទិភាពលេខ ២.៣.៤ ស្តីពីការស្ទង់មតិជាមូលដ្ឋានលើអង្គភាពនីតិកម្ម សមត្ថភាពនីតិកម្ម និងសមត្ថភាពតាក់តែងច្បាប់របស់ក្រសួងឬស្ថាប័ននីមួយៗ នៃកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ ឆ្នាំ ២០០៥។ អនុលោមទៅតាមគោលការណ៍នៃការរៀបចំសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់និងតុលាការ ដែលបានអនុម័ត កាលពីថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ កន្លងទៅ សកម្មភាពជាអាទិភាពលេខ ២.៣.៤ នេះតម្រូវអោយអនុវត្តនូវជំហានចំនួនប្រាំរួមមាន៖

១-ការរៀបចំក្រុមការងារ

២-ការធ្វើការសិក្សាស្រាវជ្រាវ

៣-ការរៀបចំរបាយការណ៍បូកសរុប និងលើកអនុសាសន៍

៤-ការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តអនុសាសន៍

៥-ការអនុវត្តផែនការសកម្មភាព ។

ឯកឧត្តមបានបញ្ជាក់ថា ដំណើរការនៃការធ្វើច្បាប់មួយមានប្រសិទ្ធភាព និងស៊ីសង្វាក់គ្នា ដោយមានការចូលរួម ផ្អែកលើវចនានុក្រមនៃច្បាប់មានការណែនាំជាក់លាក់ មានការត្រួតពិនិត្យ មានការយកចិត្តទុកដាក់ខ្ពស់លើការអនុវត្ត ស្តង់ដារអន្តរជាតិ គឺជាយុទ្ធសាស្ត្រមួយនៃទិសដៅយុទ្ធសាស្ត្រទី២ របស់កំណែទម្រង់ក្នុងការធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់។ ឯកឧត្តមបានបន្ថែមទៀតថា ការពង្រឹកអង្គភាពនីតិកម្មនៅតាមក្រសួងស្ថាប័នជុំវិញរាជរដ្ឋាភិបាល គឺជាសកម្មភាពជាអាទិភាពគន្លឹះនៃទិសដៅជាយុទ្ធសាស្ត្រទី២ ហើយជំហានចំនួន៥ ខាងលើត្រូវបានរៀបចំឡើង ដើម្បីធ្វើឱ្យសកម្មភាពលេខ ២.៣.៤ សំរេចចេញជារូបរាង ហើយឥឡូវនេះ យើងកំពុងស្ថិតនៅក្នុងជំហានទី២គឺការសិក្សាស្រាវជ្រាវ ធ្វើការស្ទង់មតិរកចន្លោះខ្វះខាត។ ឯកឧត្តមបានរំលឹកឡើងវិញអំពីគោលដៅនៃការស្ទង់មតិ គឺដើម្បីស្វែងយល់ពីបញ្ហាសំខាន់ៗចំនួនបួន៖

១-ស្ថានភាពបច្ចុប្បន្នលើការតាក់តែងច្បាប់របស់ក្រសួង និងស្ថាប័នដែលពាក់ព័ន្ធក្នុងដំណើរការតាក់តែងច្បាប់ ដូចជាក្របខណ្ឌ័ច្បាប់ យន្តការតាក់តែងច្បាប់ គោលការណ៍ណែនាំទាក់ទងទៅនឹងការតាក់តែងច្បាប់ និងធនធាននៃការតាក់តែងច្បាប់ជាដើម។

២-សេចក្តីត្រូវការដើម្បីបំពេញសមត្ថភាពនៃការតាក់តែងច្បាប់របស់អង្គភាពនីតិកម្ម

៣-ការផ្តត់ផ្គង់ដើម្បីបំពេញសមត្ថភាពនៃការតាក់តែងច្បាប់របស់អង្គភាពនីតិកម្ម

៤-វិធានការដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពនៃការតាក់តែងច្បាប់របស់អង្គភាពនីតិកម្ម។

លោកស្រី **Katharina Huebner** តំណាងអង្គការកិច្ចសហប្រតិបត្តិការបច្ចេកទេសអាឡឺម៉ង់ដ៍ (GTZ) បានមានប្រសាសន៍លើកឡើងទាក់ទងនឹងការអនុវត្តគម្រោងនេះថា នៅក្នុងឆ្នាំ ២០០៨ កន្លងទៅនេះ អង្គការ GTZ បានចុះហត្ថលេខាលើអនុសារណ: នៃកិច្ចព្រមព្រៀងមួយក្នុងការធ្វើកិច្ចសហប្រតិបត្តិការ ក៏ដូចជាការជួយគាំទ្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌រួមមានចំនួន៣សកម្មភាព៖

<u>សកម្មភាពទី១</u> ៖ ការសិក្សាបញ្ចូលប្រព័ន្ធអំប៊ូសមែន នៅប្រទេសកម្ពុជា។

<u>សកម្មភាពទី២</u> ៖ រៀបចំកែលំអគេហទំព័រ (Website) មូលដ្ឋានទិន្នន័យច្បាប់របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

<u>សកម្មភាពទី៣</u> ៖ ការស្ទង់មតិជាមូលដ្ឋានពីសមត្ថភាពនៃការតាក់តែងច្បាប់ នៅតាមអង្គភាពនីតិកម្មរបស់ក្រសួងស្ថាប័ននីមួយៗ។ ហើយដែលយើងទាំងអស់គ្នាកំពុងតែធ្វើនាថ្ងៃនេះ ដើម្បីស្វែងរកថា តើអង្គភាពនីតិកម្មមានស្ថានភាពបែបណា និងថាតើអង្គភាពនីតិកម្មមានតម្រូវការអ្វីខ្លះ? បន្ទាប់ពីការពិភាក្សាតាមក្រុម យើងនឹងបានរបាយការណ៍ ដំបូងបង្ហាញថា តើក្រសួង-ស្ថាប័ន មានតម្រូវការដូចម្តេច។ ប្រសិនឯកឧត្តម អស់លោក លោកស្រីតំណាងក្រសួង-ស្ថាប័ន ចង់បានអ្វីឬមានតម្រូវការអ្វីខាង GTZ នៅតែមានការគាំទ្រជាបន្តទៅទៀត។ លោកស្រីក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះការចូលរួមដ៏ផុសផុលរបស់ឯកឧត្តម លោកជំទាវ អស់លោកស្រីទាំងអស់ដែលបានចូលរួមបញ្ចេញមតិយោបល់ទាក់ទងនឹងការស្ទង់មតិនេះ។

ឯកឧត្តម **ម៉ែន ម៉ុនឈា** នាយករងអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានធ្វើការបង្ហាញជូនអង្គសិក្ខាសាលាអំពីដំណើរការ នៃការអនុវត្តគម្រោងតាមរយ:ការបញ្ចាំងស្លាយ ដូចឯកសារដែលបានចែកជូនអង្គសិក្ខាសាលាទាំងមូលស្រាប់។

លោក **ឥង ឥល្លះ** ជាទីប្រឹក្សាគម្រោងនៃសកម្មភាព២.៣.៤ បានធ្វើបទបង្ហាញទាក់ទិននឹងវិធីសាស្ត្រ នៃការស្រាវជ្រាវក៏ដូចជាការធ្វើការស្ទង់មតិដោយលើកឡើងថា ៖

១-ធ្វើការសិក្សាទៅលើច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ ដែលពាក់ព័ន្ធនឹងក្រសួងមានន័យថា ក្រុមការងារបានពិនិត្យមើលអនុក្រឹត្យបង្កើតក្រសួង-ស្ថាប័នទាំងអស់។ តាមការសិក្សាស្រាវជ្រាវ ក្រុមការងារសង្កេតឃើញថាអង្គភាពនីតិកម្មមានលក្ខណៈខុសៗគ្នា ក្រសួងខ្លះមានបង្កើតជាអង្គភាពនីតិកម្ម ខ្លះជានាយកដ្ឋាននីតិកម្ម ខ្លះជាការិយាល័យនីតិកម្ម ខ្លះជាក្រុមប្រឹក្សាអ្នកច្បាប់ និងក្រសួងខ្លះទៀតពុំមានតែម្តង ប៉ុន្តែគេមានក្រុមការងារសំរាប់ជួយធ្វើច្បាប់ម្តងៗតែប៉ុណ្ណោះ។ លោកបានបញ្ជាក់ជូនថា គោលបំណងនៃសិក្ខាសាលានាថ្ងៃនេះ គឺចង់ដឹងថា តើយើងគួរធ្វើយ៉ាងដូចម្តេចដើម្បីឱ្យក្រសួង-ស្ថាប័នរបស់យើងមានយន្តការរលូនដូចគ្នា? ហើយតើអង្គភាពនីតិកម្មនៅតាមក្រសួង-ស្ថាប័ន គួរតែមានរូបរាងបែបណា?

២-ដើម្បីធ្វើការសិក្សាស្រាវជ្រាវក្រុមការងារបានបង្កើតជាបញ្ជីសំណួរ ដែលបានផ្ញើជូនក្រសួង-ស្ថាប័នបំពេញនិងឆ្លើយ រួចហើយបញ្ជូនមកអោយក្រុមការងារវិញ។

៣-ក្រុមការងារនឹងចុះទៅជួបសម្ភាសន៍ផ្ទាល់តែម្តងនៅតាមក្រសួង-ស្ថាប័ន ចំនួន១៥ ហើយការសម្ភាសន៍ផ្ទាល់នេះ ចែកចេញជាបីប្រភេទគឺ ៖

១-ជាមួយមន្ត្រីជាន់ខ្ពស់

២-ជាមួយមន្ត្រីផ្នែកនីតិកម្ម

៣-ជាមួយមន្ត្រីបច្ចេកទេស។

៤-សិក្ខាសាលាថ្ងៃនេះ គឺដើម្បីស្រង់យកពត៌មានបឋម ហើយបន្ទាប់មកក្រុមការងារនឹងរៀបចំសិក្ខាសាលាម្តងទៀត ដើម្បីប្រមូលយកអនុសាសន៍ចុងក្រោយ រួចធ្វើរបាយការណ៍បញ្ចប់។

ជាបន្ទាប់ ចូលមកដល់របៀបវារៈពិភាក្សាតាមក្រុមលើបញ្ជីសំណួរដូចមានភ្ជាប់មកជាមួយស្រាប់។ ក្រោយពីក្រុមទាំង៦បានពិភាក្សាចប់សព្វគ្រប់ អង្គប្រជុំបានផ្តល់ឱកាសដល់តំណាងក្រុមនីមួយៗធ្វើរបាយការណ៍តាមក្រុមរៀងៗខ្លួន។

ក្រោយពីបានស្តាប់នូវសេចក្តីរាយការណ៍របស់ក្រុមទាំង៦រួចមក ឯកឧត្តមប្រធានបានវាយតម្លៃថា សំណួរទាំងអស់ គឺមានចម្លើយប្រហាក់ប្រហែលគ្នាច្រើន ហើយអាចយកធ្វើជាអនុសាសន៍នាពេលក្រោយបាន ហើយឯកឧត្តមបានឯកភាពទាំងស្រុងតាមអ្វីដែលក្រុមមួយចំនួនបានលើកឡើងទាក់ទងនឹងបញ្ហាធនធានមនុស្ស និងសំភារៈ ជាដើម។

ឯកឧត្តមប្រធានបានថ្លែងអំណរគុណជាអនេកកប្បការដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកនាងកញ្ញាជាសមាជិក សមាជិកាទាំងអស់ដែលបានចូលរួមពិភាក្សានិងផ្តល់អនុសាសន៍ដ៏ផុសផុល ដែលជាទុនដ៏សំខាន់សម្រាប់ក្រុមការងារយកមកពិចារណា ដើម្បីរៀបរៀងជាឯកសារទៅថ្ងៃក្រោយ។ ជាទីបញ្ចប់ឯកឧត្តមប្រធានបានជូនពរដល់

សមាជិក សមាជិកាទាំងមូលមានសុខភាពល្អបរិបូរណ៍ ប្រាជ្ញាឈ្លៀសវៃ ដើម្បីប្រកបការងារឱ្យមានប្រសិទ្ធភាពទទួលជ័យជំនះគ្រប់ភារៈកិច្ចគ្រប់ៗគ្នាកុំបីឃ្លៀងឃ្លាតឡើយ។

អង្គប្រជុំពិភាក្សានេះ បានចប់សព្វគ្រប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់នាថ្ងៃខែឆ្នាំដដែល។

**បានឃើញ និងឯកភាព**

នាយកអ.គ.គ

អ្នកធ្វើរបាយការណ៍

ស៊ុយ ម៉ុងលាង

សេង វ៉ាន់ដា

ស៊ុន សិរីវុធ

ខាងក្រោមនេះជាសំណួរ-ចម្លើយដែលក្រុមទាំងប្រាំមួយបានឆ្លើយ ដោយសរុបយកនូវមតិយោបល់ទាំងអស់មកបញ្ចូលរួមគ្នាមានជាអាទិ៖

**ផ្នែកទី១៖ ស្ថានភាពបច្ចុប្បន្នលើការតាក់តែងច្បាប់និងស្ថាប័នដែលពាក់ព័ន្ធក្នុងដំណើរការតាក់តែង ច្បាប់ (ដូចជាក្របខណ្ឌច្បាប់, យន្តការតាក់តែងច្បាប់ គោលការណ៍ណែនាំទាក់ទងនឹង ការតាក់តែងច្បាប់ និងធនធាននៃការតាក់តែងច្បាប់ជាដើម)**

**១.តើអ្នកយល់យ៉ាងណាដែរចំពោះពាក្យ «អង្គភាពនីតិកម្ម» នៅតាមក្រសួង?**

ក-អង្គភាពទាក់ទងនិង កិច្ចការច្បាប់ (អង្គភាពស្នូល)៖ ថ្នាក់ណាក៏បានដែរ

-មានឋានៈច្បាស់លាស់

-មានរចនាសម្ព័ន្ធច្បាស់លាស់

ខ-នាយកដ្ឋានកិច្ចការច្បាប់

- មន្ត្រីអង្គភាពនីតិកម្មត្រូវតែជាមន្ត្រីជាន់ខ្ពស់

គ-អគ្គនាយកដ្ឋាននីតិកម្ម (អង្គភាពបច្ចេកទេស)

ឃ-ក្រុមប្រឹក្សានីតិកម្ម (ប្រមូលផ្តុំមន្ត្រីជាន់ខ្ពស់)

-សុំឱ្យក្រសួងទាំងអស់មានរចនាសម្ព័ន្ធដូចគ្នា ត្រូវមានសារាចរណែនាំអោយបង្កើត

-មានអ្នកបច្ចេកទេស និងអ្នកច្បាប់

-ឋានៈនាយកដ្ឋានពិបាកធ្វើការសម្របសម្រួល

-គិតពីទំហំការងារទៅក្រសួងដើម្បីកំណត់អង្គភាពនីតិកម្ម

**២.តើអង្គភាពនីតិកម្មនៅក្នុងក្រសួងរបស់លោកអ្នកមានតួនាទីធ្វើអ្វីខ្លះ?**

-រៀបចំទម្រង់ច្បាប់ (ចំណែកខ្លឹមសារនៅលើនាយកដ្ឋានជំនាញ)

-ពិនិត្យច្បាប់ និងលិខិតបទដ្ឋានចុងក្រោយ

-សម្របសម្រួលការតាក់តែងច្បាប់ ឬលិខិតបទដ្ឋានជាមួយអង្គភាពផ្សេងៗ ផ្តល់ផ្នែកបច្ចេកទេសដល់ក្រសួង

-ស្រាវជ្រាវច្បាប់របស់ក្រសួង និងចងក្រង

-ចូលរួមកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល

-ទំនាក់ទំនងអន្តរជាតិ និងច្បាប់អន្តរជាតិ

-ការពិគ្រោះយោបល់មុននឹងធ្វើច្បាប់

-បោះពុម្ពផ្សព្វផ្សាយតាមគ្រប់រូបភាព

-បណ្តុះបណ្តាលអប់រំ

-សហការជាមួយព្រះរាជអាជ្ញា (ស្ថាប័នអយ្យការ)

-តាមដានការអនុវត្តច្បាប់

-តាមដាន និងត្រួតពិនិត្យច្បាប់ទាក់ទងនឹងការវិវត្តថ្មីៗរបស់ពិភពលោក និងបទដ្ឋានទាក់ទងនឹងវិស័យគមនាគមន៍

-លើកគម្រោងតាក់តែងច្បាប់

-មិនទាន់បានកសាងសេចក្តីព្រាងច្បាប់ មានតែលិខិតបទដ្ឋានផ្សេងៗ

-ពុំធ្លាប់មានគំនិតផ្តួចផ្តើមទេ

-ត្រួតពិនិត្យ និងផ្សព្វផ្សាយច្បាប់

-ផ្តួចផ្តើមសេចក្តីព្រាងច្បាប់ដោយនាយកដ្ឋានជំនាញ

-ផ្តួចផ្តើម និងផ្តល់យោបល់នៅពេលប្រជុំ

-ចូលរួមបង្កើតបទប្បញ្ញត្តិប្រកាសសេចក្តីណែនាំ

-នាយកដ្ឋានជំនាញជាអ្នកផ្តួចផ្តើមធ្វើសេចក្តីព្រាងច្បាប់ ដោយមានអ្នកជំនាញផ្សេងៗចូលរួម

-សិក្សាស្រាវជ្រាវ ឯកសារច្បាប់គ្រប់វិស័យគ្រប់ជំនាន់ ទាំងក្នុង និងក្រៅប្រទេស

-សេនាធិការឱ្យក្រុមប្រឹក្សាយោធា ក្នុងការអនុវត*្តលក្ខន្តិកៈទូទៅ

-សហការជាមួយបណ្តានាយកដ្ឋាន

-រៀបចំរបាយការណ៍អនុវត្តច្បាប់

-តាមដានជំរុញកងឯកភាពឱ្យផ្សព្វផ្សាយខ្លឹមសារច្បាប់

-ដោះស្រាយវិវាទ

-គ្រប់គ្រងឯកសារច្បាប់។

**៣.តើយន្តការនៃការតាក់តែច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ នៅក្រសួងរបស់លោកអ្នកមានអ្វីខ្លះ? ហើយតើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិចាប់ផ្តើមធ្វើពីណា?**

-នាយកដ្ឋាន

-ការិយាល័យ

-ការិយាល័យនីតិកម្ម

-ការិយាល័យគតិយុត្តចំណុះអគ្គលេខាធិការដ្ឋាន (ធនាគារជាតិ)

-ក្រុមប្រឹក្សា

-ក្រុមការងារ គណៈកម្មាការ (ក្រសួងអភិវឌ្ឍន៍ជនបទ )

-មន្រ្តីជំនាញ

-សេចក្តីណែនាំរបស់ក្រសួងអប់រំយុវជន និងកីឡា

-ប្រកាសក្រសួងប្រៃសណីយ៍

-ស្តង់ដារអន្តរជាតិ

-ការធ្វើលិខិតបទដ្ឋានភាគច្រើនចេញពីអង្គភាព

-ការធ្វើច្បាប់ចេញអង្គភាពនីតិកម្ម

-នីតិវិធីធ្វើលិខិតបទដ្ឋាន ៖

ក-អង្គភាពជំនាញនាញ អង្គភាពនីតិកម្ម គណៈកម្មាការរបស់ក្រសួង គណៈរដ្ឋមន្ត្រី

ខ-អង្គភាពនីតិកម្មកម្ម  អង្គភាពជំនាញ  ថ្នាក់ដឹកនាំ គណៈរដ្ឋមន្ត្រី

គ-ក្រុមការងារ  ថ្នាក់ដឹកនាំ

**៤.តើក្រសួងរបស់លោកអ្នកមានការលំបាកអ្វីខ្លះនៅពេលធ្វើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ?**

-ខ្វះធនធានមនុស្ស

-ខ្វះថវិកា

-ខ្វះការលើកទឹកចិត្ត-ការគាំទ្រ

-ខ្វះគោលការណ៍ណែនាំ-វិធីសាស្ត្រតាក់តែងច្បាប់

-ខ្វះសម្ភារៈ

-ខ្វះកិច្ចសហការ និងការយកចិត្តទុកដាក់

-ខ្វះកន្លែងធ្វើការសមរម្យ។

**៥.តើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិភាគច្រើនត្រូវបានធ្វើដោយអ្នកជំនាញការបរទេស ឬអ្នកជំនាញការជាតិ?**

-ច្បាប់ធំៗទាក់ទងនឹងច្បាប់អន្តរជាតិធ្វើដោយអ្នកជំនាញការបរទេស

-លិខិតបទដ្ឋានផ្សេងៗដោយអ្នកជំនាញការខ្មែរ

-ភាគច្រើននៃការធ្វើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋាន ចេញពីអ្នកជំនាញកម្ពុជា ដោយសហការជាមួយបរទេស (ជួនកាលមិនសហការ) (ជ្រើសរើសអនុសាសន៍)

-ជំនាញការជាតិ (៤/៩)

-ជំនាញបរទេស (៨/៩)

-សហការគ្នារវាងជំនាញការជាតិ និងបរទេស (៩/៩)

-សេចក្តីព្រាងច្បាប់គតិយុត្ត ត្រូវបានធ្វើដោយទាំងជំនាញការជាតិ និងជំនាញការអន្តរជាតិ ហើយភាគច្រើនដោយជំនាញការបរទេសលើកលែងតែក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។

## ផ្នែកទី២៖ សេចក្តីត្រូវការដើម្បីបំពេញសមត្ថភាពនៃការតាក់តែងច្បាប់របស់អង្គភាពនីតិកម្ម

**១.តើអង្គភាពនីតិកម្មចាំបាច់ត្រូវតែមាននៅតាមក្រសួងឬទេ? ប្រសិនបើចាំបាច់តើត្រឹមកំរិតណា?**

-ចាំបាច់ទៅតាមទំហំការងារ

-ត្រូវការចាំបាច់អង្គភាពនីតិកម្ម កម្រិតនាយកដ្ឋាន

-ចាំបាច់ត្រូវតែមានអង្គភាពនីតិកម្មក្នុងក្រសួងនីមួយៗ

-ចាំបាច់ត្រូវមានជាលក្ខណៈស្តង់ដាមួយជាក់លាក់ និងឯករាជ្យ និងចែងច្បាស់លាស់ពីតួនាទី និងភារកិច្ចដែលបង្កើតឡើងដោយអនុក្រឹត្យ (ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងស្ថាប័ន)

-អគ្គនាយកដ្ឋាន

-ចាំបាច់ (៩/៩)

-ក្រុមប្រឹក្សានីតិកម្ម (៣/៩)

-នាយកដ្ឋាននីតិកម្ម (៦/៩)

-ការិយាល័យនីតិកម្ម (0)។

**២.តើមានមូលហេតុអ្វីខ្លះដែលក្រសួងរបស់លោកអ្នកចាំបាច់ត្រូវមានអង្គភាពនីតិកម្ម?**

*មូលហេតុបានឆ្លើយតាមផ្នែកទី១*

-អោយមានការគ្រប់គ្រងល្អ

-ត្រួតពិនិត្យការធ្វើច្បាប់អោយបានត្រឹមត្រូវ

-បង្កើនសេដ្ឋកិច្ច

-ដើម្បីការពារវិនិយោគសាធារណៈ

-រដ្ឋាភិបាលជាអ្នករៀបចំសេចក្តីព្រាងច្បាប់

-ជាសេនាធិការផ្នែកច្បាប់របស់ក្រសួងស្ថាប័ន (Lawyer of Ministries /Institution )

-ចងក្រងឯកសារ

-សង្គតិភាពនៃការតាក់តែងច្បាប់(ស៊ីសង្វាក់)

-មានតម្លាភាព

-មានការងាយស្រួលក្នុងការផ្តល់អង្គភាពជំនាញ

-ការពារអំណាចក្រសួងស្ថាប័ន

-ធ្វើវិសោធនកម្មច្បាប់

-កសាងច្បាប់ផ្សេងៗឱ្យស្របទៅតាមការវិវឌ្ឍនៃសេដ្ឋកិច្ចសង្គម។

**៣.សេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិទាំងអស់មានការចូលរួមផ្តល់យោបល់ពីអង្គភាពនីតិកម្មឬទេ?**

*បានឆ្លើយ ៖*

-មានប្រមាណ ៥0 ភាគរយ

-មានការចូលរួមពីអង្គភាពនីតិកម្ម (0)

-ចូលរួមមិនពេញលេញ (៦/៩)

-គ្មានការចូលរួមពីអង្គភាពនីតិកម្ម (៣/៩)

-ត្រូវតែមានការចូលរួមឆ្លងយោបល់ពីអង្គភាពនីតិកម្ម

-0៤ ក្រសួងមិនឆ្លងនីតិកម្ម

-0៨ ក្រសួងឆ្លងនីតិកម្ម។

**៤.តើក្រសួងរបស់លោកអ្នកមានសេចក្តីត្រូវការអ្វីខ្លះដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត?**

*ទាក់ទងការលំបាក ៖*

-ធនធានមនុស្ស-បណ្តុះបណ្តាល-កម្មសិក្សា

-ប្រាក់ឧបត្ថម្ភ

-សម្ភារ:

-ឯកសារស្រាវជ្រាវ

-យន្តការតាក់តែងច្បាប់

-ខ្វះឯករាជ្យភាព

-ការសហការទំនាក់ទំនងល្អ និងការយកចិត*្តទុកដាក់

-ការគាំទ្រពីក្រសួងហិរញ្ញវត្ថុ

-ជំនួយបរទេស

-នីតិវិធីធ្វើច្បាប់

-វិធីសាស្ត្រធ្វើច្បាប់

-ខ្វះឯកសារ

-ខ្វះកន្លែងធ្វើការសមរម្យ

-បណ្តុះបណ្តាលមន្ត្រីក្នុងអង្គភាពនីតិកម្ម (វគ្គខ្លី មធ្យម វែង)

-ប្រើប្រាស់មន្ត្រីអោយចំជំនាញ ធ្វើឯកទេសកម្មទៅតាមការិយាល័យជំនាញច្បាប់

-មានការលើកទឹកចិត្តសមស្រប

**៥.តើសេចក្តីត្រូវការចាំបាច់ជាអាទិភាពនៃក្រសួងរបស់លោកអ្នកមានអ្វីខ្លះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពតាក់តែងច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ?**

- នីតិវិធីណែនាំធ្វើច្បាប់

-ការបណ្តុះបណ្តាលរបៀបធ្វើច្បាប់

-ការលើកទឹកចិត្ត (តួនាទី និងប្រាក់ឧបត្ថម្ភ)

-ធនធានមនុស្ស

-សំភារ:

-ហិរញ្ញវត្ថុ

-ស្វែងរកដៃគូអភិវឌ្ឍលើផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ

-រាជរដ្ឋាភិបាលត្រូវមានកញ្ចប់ថវិកាក្នុងការគាំទ្រសមត្ថភាពធ្វើច្បាប់

-ត្រូវមានផែនការច្បាស់លាស់ក្នុងការតាក់តែងច្បាប់ និងលិខិតបទដ្ឋាន

-ឯករាជ្យភាព។

**ផ្នែកទី ៣៖ ការផ្តល់ផ្គង់ដើម្បីបំពេញសមត្ថភាពនៃការតាក់តែងច្បាប់របស់អង្គភាពនីតិកម្ម**

**១.តើអង្គភាពនីតិកម្មបានផ្តល់ជំនួយបច្ចេកទេសអ្វីខ្លះដល់អង្គភាពជំនាញ នៅពេលធ្វើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ហើយផ្តល់ដោយវិធីណា?**

-ជួយមតិយោបល់

-ជួយព្រាងយោបល់

-ជួយកែលំអរ

-វិធីផ្តល់បច្ចេកទេស: តាមរយៈឯកសារ តាមការចូលរួម

-ធ្វើការជាមួយគ្នា-ផ្តល់ជាឯកសារ-យោបល់

-ជំនាញឆ្លងនីតិកម្មដើម្បីសុំយោបល់

-ខ្វះកិច្ចសហប្រតិបត្តិការ (ដោយសារមិនទាន់មានកំណត់ច្បាស់លាស់ចំពោះភារៈកិច្ចរបស់អង្គភាពនីមួយៗ)

-មានផ្តល់ជំនួយបច្ចេកទេសខាងច្បាប់ ផ្តល់យោបល់ និងឯកសារពាក់ព័ន្ធ

- តាមរយៈការចូលរួម និងកិច្ចប្រជុំ
- ចូលរួមផ្តល់យោបល់ផ្នែកច្បាប់ជាមួយនាយកដ្ឋានជំនាញធ្វើច្បាប់ផ្ទាល់
- ចូលរួមការងារក្នុងអន្តរនាយកដ្ឋានតាមការចាត់តាំងរបស់រដ្ឋមន្ត្រី
- ផ្តលយោបល់លើសេចក្តីព្រាងលើលិខិតបទដ្ឋានគតិយុត្តិ

-ផ្តល់ការបណ្តុះបណ្តាលផ្នែកច្បាប់ដល់មន្ត្រីជំនាញ

-ជួយធ្វើសន្ទានុក្រម

-គ្មានជំនួយបច្ចេកទេសផ្តល់ឱ្យអង្គភាពទេ(ក្រុម២)

**២.តើអង្គភាពជំនាញបានទទួលជំនួយបច្ចេកទេសអ្វីខ្លះពីអង្គភាពនីតិកម្ម នៅពេលធ្វើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ហើយផ្តល់ដោយវិធីណា?**

-ដូចទី១

-គ្មានជំនួយបច្ចេកទេសផ្តល់ឱ្យអង្គភាពទេ(ក្រុម២)

-ចូលរួមមតិ

-ឯកសារ

-ជួយធ្វើ និងជួយការពារ។

ក.បានទទួលចំលើយសំណួរទី១ និងទទួលបានគោលការណ៏ច្បាប់

ខ.ផ្តល់វិធីសាស្ត្រ

-ប្រជុំក្រុមការងារ

-សន្និបាតបាតក្នុងក្រសួង

-វេទិការតុមូល។

-បានទទួលឯកសារច្បាប់ដែលមិនស្ថិតនៅក្នុងជំនាញរបស់អង្គភាពជំនាញ

-បានទទួលកិច្ចសហការសំរបសំរួលក្នុងការតាក់តែងលិខិតបទដ្ឋានគតិយុត្ត។

**៣.តើអង្គភាពនីតិកម្មបានទទួលជំនួយបច្ចេកទេសពីអង្គភាពផ្សេងៗនៅពេលធ្វើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិឬទេ? តើមានជំនួយអ្វីខ្លះ?**

-បច្ចេកទេស (ពត៏មានទាក់ទង និងច្បាប់ ឬលិខិតបទដ្ឋាន)

-យោបល់ឯកទេស

-អនុសាសន៏-បទពិសោធន៏-ជំនាញ

-ជំនួយស្មារតី

-សំភារៈ ឯកទេស (អង្គការដៃគូរជាអ្នកឧបត្ថម្ភ)

-អង្គភាពជំនាញទទួលជំនាញបច្ចេកទេសពីអង្គភាពនីតិកម្ម (៥០ ភាគរយ ទៅ ៨០ ភាគរយ)

-ឯកសារជំនាញគ្រប់ប្រភេទ

-មាន (ប្រជុំ និងឯកសារ)(ក្រុម ៣)

-មិនធ្លាប់មាននៅក្នុងនាយកដ្ឋាននីតិកម្ម ប៉ុន្តែធ្លាប់មានក្នុងក្របខ័ណ្ឌក្រសួង(ក្រុម ២)

**៤.តើក្រសួងរបស់លោកអ្នកបានទទួលជំនួយពីក្រសួងផ្សេងទៀតនៅពេលធ្វើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិឬទេ?**

-វិស័យឯកជន

-បច្ចេកទេសពីក្រសួងពាក់ព័ន្ធ

-មានជំនួយបច្ចេកទេសពីក្រសួងផ្សេង។ ឧទាហរណ៏ ៖ ច្បាប់ប្រឆាំងអំពើពុករលួយមាន ជំនួយបច្ចេកទេស ពីក្រសួង យុត្តិធម៌ និងក្រសួងមហាផ្ទៃ

-មាន(ប្រជុំ និងឯកសារ)

-មាន

-បានទទួលយោបល់ (ដោយពិគ្រោះយោបល់)

-សហការ

-ផ្តល់ឯកសារ

- យោបល់ពីសហគមន៏
- អនុសាសន៏លើសង្គមសីវិល និងដៃគូអភិវឌ្ឍ
- អនុសាសន៏ពីអាជ្ញាធរដែនដី
- អនុសាសន៏ពីអាជ្ញាធរ គណៈកម្មការ ក្រុមប្រឹក្សាពាក់ព័ន្ធ។

**ផ្នែកទី៤៖ ចនាការដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពនៃការតាក់តែងច្បាប់ និងលិខិតបទដ្ឋាន ផ្សេងៗរបស់អង្គភាពនីតកម្ម**

**១.តើមានវិធានការអ្វីខ្លះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពតាក់តែងច្បាប់ និងលិខិតបទដ្ឋានផ្សេងៗរបស់ ក្រសួង?**

-លើកកំពស់អង្គភាពនីតិកម្ម

-ត្រូវមានមន្រ្តីជំនាញច្បាប់

-កិច្ចសហការល្អពីអង្គភាពផ្ទៃក្នុង និងក្រសួង

-យន្តការច្បាស់លាស់នៃការតាក់តែងច្បាប់

-បណ្តុះបណ្តាលទាំងក្នុង និង ក្រៅប្រទេស

-បង្កើតអង្គភាពនីតិកម្ម(ចំពោះក្រសួងដែលគ្មានអង្គភាពនីតិកម្ម)

-ត្រូវមានថវិការសម្ភារៈគ្រប់គ្រាន់សម្រាប់ដំណើរការ

-ចែករំលែកបទពិសោធន៏ទៅវិញទៅមកតាមរយៈសិក្ខាសាលា និងវេទិកាផ្សេងៗ

-រួមសហការពីជំនាញការបរទេស ដៃគូរអភិវឌ្ឍន៏

-ទស្សនៈកិច្ចសិក្សាក្នុង និងក្រៅប្រទេសដើម្បីផ្លាល់ប្តូរបទពិសោធន៏។

**២.តើមានវិធានការអ្វីខ្លះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវអង្គភាពនីតិកម្មរបស់ក្រសួង?**

*<u>បានឆ្លើយរួចហើយ</u>*

-អង្គភាពនីតិកម្មជាអង្គភាពអាទិភាពរបស់ក្រសួង ពង្រឹង និងបង្កើតសមត្ថភាព និងតួនាទី(ណែនាំ-ត្រួតពិនិត្យ-អនុវត្ត -ផ្សព្វផ្សាយជាលក្ខណៈប្រព័ន្ធ )

-គោលការណ៏លើកទឹកចិត្ត.ផ្តល់តួនាទីសមស្រប ដាក់អោយចំជំនាញ និងតាមបទពិសោធន៏

-កសាងសម្ថភាព

-ផ្តល់ឯករាជ្យភាពដល់អង្គភាពនីតិកម្ម

-រាល់លិខិតបទដ្ឋានគតិយុត្តិ ត្រូវឆ្លងយោបល់ទៅតាមឋានុក្រមអង្គភាពនីតិកម្ម

-គួររៀបចំសារាចរណ៏ ណែនាំពីនីតិវិធីកសាងលិខិតបទដ្ឋានគតិយុត្តិក្នុងក្របខ័ណ្ឌក្រសួងស្ថាប័ននីមួយៗ

-បង្កើនតម្លៃអង្គភាពនីតិកម្ម (ផ្តល់អំណាច និងការលើទឹកចិត្ត)

-បែងចែកកញ្ចប់ថវិការឱ្យច្បាស់លាស់ ហើយច្រើន

-កន្លែងធ្វើការ និងសំភារៈសមរម្យ

-ផ្គត់ផ្គង់ឱ្យមន្ត្រីមានលទ្ធភាពរស់

-ពង្រឹងស្ថាប័ន

-គំនិតផ្តួចផ្តើមក្នុងការកសាងច្បាប់តាមវិស័យ

-ក្រមសីលធម៏វិជ្ជាជីវៈសំរាប់មន្ត្រីនីតិកម្ម៕